# តេជះខ្ញុំសាង

តេជះខ្ញុំសាង សំអិតសំអាង ឱនកាយវាចា
សូមសុខសុភាព រួចពីទុក្ខា ឆ្លងដល់ត្រើយមហា
ពោលគឺនិព្វាន ។

គ្រប់ជាន់គ្រប់ជាតិ កុំឱ្យខ្ញុំឃ្លាត ពីសីលនិងទាន
គំនិតខ្ញុំកើត កំណើតខ្ញុំមាន មគ្គផលជាស្ពាន
ដល់ឋានថ្លៃថ្លា ។

ខ្ញុំជូនមគ្គផល ចំពោះទៅដល់ មាតាបិតា
គុណគ្រូឧប- ជ្ឈាយាចារ្យ គុណញាតិកា
ប្រាំពីរសន្តាន ។

ជីដូនជីតា រស់នៅក្តីណា លោកម្ចាស់ចែកឋាន
ខ្ញុំជូនមគ្គផល កុសលថ្កើងថ្កាន សូមសុខក្សេមក្សាន្ត
ដល់ឋានផុតទុក្ខ ។

វត្តធម្មារាម



ដកស្រង់និងចងក្រងដោយខ្ញុំបាទ **ទ៉ាន់ អ៊ុន** អាចារ្យទី១សម្រាប់វត្តធម្មារាម ក្រុងស្តុកតុន រដ្ឋកាលីហ្វរនីញ៉ា ព.ស.២៥៤៣

វាយចម្លងដាក់គេហទំព័រវត្តដោយខ្ញុំបាទ **អ៊ិន ឈី** ថ្ងៃទី១៦ ខែមីនា គ.ស.២០១២